# ពួកសាវ័កដែលខ្ពស់ជាគេបង្អស់ត្រូវបានចាត់តាំង

អែលឌើរ វីល្លាម អរ វ៉កឃើរ
នៃក្រុម 70 នាក់

*ប្រាជ្ញា និងកម្លាំងនឹងមានមកដល់យើង នៅពេលយើងមើលទៅគណៈប្រធានទីមួយ ធ្វើជាគំរូដ៏ល្អ និងជាគំរូនៃភាពជាអ្នកដឹកនាំរបស់យើង ។*

វាជាពរជ័យ និងជាឱកាសដ៏អស្ចារ្យសំរាប់យើង ដើម្បីគាំទ្រដល់ប្រធាន ថូម៉ាស អេស ម៉នសុន ប្រធាន ហ៊ែនរី ប៊ី អាវរិង និងប្រធាន ដាយថើ អេស្វ អុជដូហ្វ ជាគណៈប្រធានទីមួយថ្មីនៃសាសនាចក្ររបស់ព្រះអម្ចាស់ ។

កាលពីដំបូងខ្ញុំបានរៀនអំពីសារៈសំខាន់នៃគណៈប្រធានទីមួយ ពេលខ្ញុំនៅជាក្មេងដែលធំឡើងនៅភាគខាងលិចនៃប្រទេសកាណាដា ។ នៅពេលដែលខ្ញុំទៅផ្ទះរបស់លោកយាយលោកតា វ៉កឃើរ ខាងឪពុករបស់ខ្ញុំ ពេលខ្ញុំដើរចូលផ្ទះខ្ញុំត្រូវបានស្វាគមន៍ដោយរូបថតរបស់គណៈប្រធានទីមួយនៃសាសនាចក្រ ។ ខ្ញុំចងចាំរឿងនោះបានល្អណាស់ ។ វាហាក់ដូចជា ពួកលោកឈរចាំស្វាគមន៍ដល់ជនទាំងឡាយណា ដែលបានដើរចូលដូច្នោះដែរ ។

រូបថតពណ៌ធម្មជាតិដ៏ស្រស់ស្អាតនោះគឺជារូបថតនៃប្រធាន ចច អ័លប៊ើត ស្ម៊ីធ ជាមួយនឹងទីប្រឹក្សាទាំងពីររបស់លោក គឺប្រធាន ជេ រ៉ូប៊ីន ក្លាក ជុញ្ញ័រ និងប្រធាន ដាវីឌ អូ មិកឃេ ។ រូបថតនោះបានបង្ហាញរូប ពួកលោកឈរជាមួយគ្នា នៅជិតរូបផែនទីពិភពលោកដ៏ធំមួយ ។ ខ្ញុំចូលចិត្តរូបថតនោះ ។ ពួកលោកជាបុរសសង្ហារ ហើយមានសេចក្ដីថ្លៃថ្នូរណាស់ ខ្ញុំដឹងថាលោក និងទីប្រឹក្សារបស់លោកគឺជាព្យាការីនៃព្រះ ។

រូបថតព្យួរនៅខាងមុខបន្ទប់ទទួលភ្ញៀវនៅផ្ទះរបស់លោកយាយលោកតារបស់ខ្ញុំនោះ បានជះឥទ្ធិពលយ៉ាងខ្លាំងមកលើរូបខ្ញុំ ។ ខ្ញុំបានរស់នៅទីក្រុងដែលមានវាលស្មៅតូចមួយនៅរ៉េម៉ន ជាកន្លែងដែលលោកយាយ លោកតារបស់ខ្ញុំបានរស់នៅ ។ ខ្ញុំអាចដើរទៅផ្ទះរបស់ពួកគាត់បាន ដូច្នេះខ្ញុំបានទៅលេងគាត់ជាញឹកញាប់ ។ ខ្ញុំចាំថា ជាញឹកញាប់ខ្ញុំដោយឈរយ៉ាងស្ងប់ស្ងាត់ម្នាក់ឯង នៅក្នុងបន្ទប់ទទួលភ្ញៀវនោះ សម្លឹងមើលទៅរូបថត របស់គណៈប្រធានទីមួយដោយសេចក្ដីគោរព ។ ខ្ញុំនៅចាំកាលដែលគិតថាតើហេតុអ្វីលោកយាយលោកតារបស់ខ្ញុំគិតថា វាមានសារៈសំខាន់ដើម្បីគោរពដល់គណៈប្រធានទីមួយ និងមានរូបថតដ៏សំខាន់នោះដាក់តាំងនៅក្នុងផ្ទះរបស់ពួកគាត់ ។ អ្នកទាំងឡាយដែលដើរចូលផ្ទះរបស់គាត់នឹងឃើញរូបថតនោះ ។ ប្រហែលអ្វីដែលសំខាន់បំផុតនោះគឺសំរាប់កូនៗ និងចៅៗរបស់ពួកគាត់ ហើយរូបភាពនោះគឺជាការរំលឹកយ៉ាងខ្ជាប់ខ្ជួន នៃអ្វីដែលមានសារៈសំខាន់បំផុតនៅក្នុងបេះដូង និងជីវិតរស់នៅរបស់លោកយាយ និងលោកតា ។

ជាច្រើនឆ្នាំក្រោយមក ខ្ញុំបានសន្និដ្ឋានថា ការដាក់តាំងរូបថតរបស់គណៈប្រធានទីមួយ គឺដូចទៅនឹងការបង្ហាញដ៏ល្អរបស់យ៉ូស្វេថា: "ចូររើសយកព្រះណាដែលឯងចង់គោរពប្រណិបត្តិតាមនៅថ្ងៃនេះចុះ ។ ឯអញ និងពួកគ្រួសារអញយើងទាំងអស់គ្នានឹងគោរពប្រណិបត្តិដល់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ" (យ៉ូស្វេ 24:15) ។

អ្នកទាំងអស់ណាដែលចូលទៅក្នុងផ្ទះរបស់លោក ជេម និងបងស្រី ហ្វែននី រីកយើរ បានដឹងថា ពាក្យសំដីមួយដែលបានចារនៅក្នុងបេះដូងរបស់ពួកគាត់គឺ: "ឯយើង និងគ្រួសារយើង យើងទាំងអស់គ្នានឹងគោរពប្រណិបត្តិដល់ព្រះយេហូវ៉ាមួយតែប៉ុណ្ណោះ"។ ក្នុងនាមជាចៅប្រុសរបស់ពួកគាត់ ខ្ញុំយល់ពាក្យទាំងនេះ ហើយខ្ញុំមិនដែលភ្លេចឡើយ។

កាលពីនៅក្មេង ខ្ញុំមិនសូវបានយល់អំពីសារៈសំខាន់ នៃការមានបុរសបីរូបនៅក្នុងគណៈប្រធានទីមួយ ជាជាងការមានប្រធានតែម្នាក់នោះទេ។ ប្រាកដណាស់ ខ្ញុំដឹងថាព្រះយេស៊ូវបានជ្រើសរើស ពេត្រុស យ៉ាកុប និងយ៉ូហាន មិនមែនគ្រាន់តែពេត្រុសម្នាក់នោះទេ។ ខ្ញុំបានដឹងថា ឪពុករបស់ខ្ញុំគឺជាបុរសម្នាក់នៅក្នុងចំណោមបុរសបីនាក់នៃគណៈប៊ីស្សព បំរើជាទីប្រឹក្សារបស់ប៊ីស្សព ជេ អូ ហ៊ីកខែន។

ខ្ញុំបានដឹងថា លោកតារបស់ខ្ញុំគឺជាប្រធានស្តេក ហើយលោកមានទីប្រឹក្សាពីររូប ដែលបានឈរនៅក្បែរលោក (ប្រធាន ចន អាលែន និងប្រធាន លេស្លី ផាមើរ)។

នៅក្នុងគ្រប់ករណីទាំងអស់--- *គណៈប្រធាន* --- មិនគ្រាន់តែមានបុរសម្នាក់ជាអ្នកដឹកនាំនោះទេ ប៉ុន្តែមានបុរសបីនាក់ ដែលដឹកនាំការងារជាមួយគ្នា។ នៅថ្នាក់អង្គការបឋមសិក្សា ខ្ញុំបានរៀនមាត្រានៃសេចក្តីជំនឿ ហើយចូលចិត្តវាណាស់។ មាត្រានៃសេចក្តីជំនឿ ផ្តល់ដល់យុវវ័យរបស់យើងនូវការលួងលោមចិត្ត និងទំនុកចិត្ត នៅពេលពួកគេរៀនអំពីគោលលទ្ធិគ្រឹះទាំងឡាយនៃសាសនាចក្រ។ រួចមកខ្ញុំដឹងថា "បុរសម្នាក់ត្រូវតែបានហៅពីព្រះ ដោយការព្យាករណ៍ និងដោយការដាក់ដៃលើ ដោយអស់អ្នកណាដែលមានសិទ្ធិអំណាច ដើម្បីនឹងផ្សាយដំណឹងល្អ ហើយប្រព្រឹត្តពិធីការទាំងឡាយនៃដំណឹងល្អ" (មាត្រានៃសេចក្តីជំនឿ 1:5)។

នៅឆ្នាំ 1835 ព្រះអម្ចាស់បានបើកសម្តែងចំពោះព្យាការី យ៉ូសែប ស្ម៊ីធ នូវលំដាប់ត្រឹមត្រូវ នៃគណៈប្រធាននៅក្នុងសាសនាចក្រ:

"មកពីការចាំបាច់ទើបមានពួកប្រធាន ឬពួកអ្នកកាន់តំណែងត្រួតត្រា...។ មកពីបព្វជិតភាពមិលគីស្សាដែកគឺមានពួកសង្ឃជាន់ខ្ពស់ត្រួតត្រាបីនាក់ ដែលបានរើសឡើងដោយក្រុម គឺបានតាំង ហើយតែងតាំងឡើងចំពោះតំណែងនោះ ហើយគាំទ្រដោយសេចក្តីទុកចិត្ត សេចក្តីជំនឿ និងសេចក្តីអធិស្ឋាន នៃសាសនាចក្រឱ្យធ្វើជាក្រុមក្នុងគណៈប្រធាននៃសាសនាចក្រ" (គ. និង ស. 107:21--22)។

"ក្រុមរបស់ប្រធានទាំងបី" (គ. និង ស. 107: 29)---មិនមែនមានតែប្រធានមួយរូប ហើយអនុប្រធានពីររូបនោះទេ---ប៉ុន្តែមានពួកសង្ឃជាន់ខ្ពស់ត្រួតត្រាបីនាក់។ ក្រុមមួយរបស់ប្រធានទាំងបី--- គណៈប្រធានទីមួយនៃសាសនាចក្ររបស់ព្រះអម្ចាស់។

ពិភពលោកមិនបានរៀបចំតាមវិធីនេះទេ ប៉ុន្តែនេះគឺជារបៀបដែលព្រះអម្ចាស់បានរៀបចំ ហើយដាក់រចនាសម្ព័ន្ធសាសនាចក្ររបស់ទ្រង់។

រឿងនេះធ្វើឱ្យខ្ញុំនឹកឃើញនូវព្រះគម្ពីរមួយថា: "ពីព្រោះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា គំនិតអញមិនមែនដូចជាគំនិតរបស់ឯងរាល់គ្នាទេ ឯផ្លូវរបស់ឯងរាល់គ្នា ក៏មិនមែនជាផ្លូវរបស់អញដែរ។ ត្បិតដែលផ្ទៃមេឃខ្ពស់ជាងផែនដីយ៉ាងណា នោះអស់ទាំងផ្លូវរបស់អញ ខ្ពស់ជាងផ្លូវរបស់ឯង ហើយគំនិតរបស់អញ ក៏ខ្ពស់ជាងគំនិតរបស់ឯងរាល់គ្នាយ៉ាងនោះដែរ" (អេសាយ 55:8--9)។

ប្រហែលជានៅខួបកំណើតលើកទីប្រាំពីររបស់ខ្ញុំ ខ្ញុំបានរៀនបន្តិចបន្តួចអំពីការស្នងតំណែងនៅក្នុងគណៈប្រធាន នៅពេលដែលប្រធាន ចច អ័លបើត ស្ម៊ីធ បានទទួលមរណភាព។ មួយរយៈក្រោយមក រូបថតនៅ ក្នុងបន្ទប់ទទួលភ្ញៀវរបស់លោកយាយលោកតា ត្រូវបានផ្លាស់ប្ដូរដោយរូបថតដ៏ស្រស់ស្អាតនៃប្រធាន ដាវីឌ អូ មិកឃេ និងទីប្រឹក្សារបស់លោក គឺប្រធាន ស្ទេបហ្វិន អិល រីឆាត និងប្រធានជេ រ៉ូបឹន ក្លាក ជុញ៉ រ។

កាលពីនៅក្មេង ខ្ញុំពិតជាមិនបានយល់ឱ្យបានស៊ីជំរៅអំពីសារៈសំខាន់ ឬដំណើរការនៃការស្នងតំណែងនៅក្នុងគណៈប្រធាន ទេ---ប៉ុន្តែខ្ញុំបានដឹងថា ព្យាការីបានទទួលមរណភាព ហើយយើងត្រូវបានដឹកនាំដោយព្យាការីថ្មីនៃព្រះជាមួយនឹង ទីប្រឹក្សាពីររូប នៅក្បែរលោក។

នៅអាយុ 13 ឆ្នាំ ខ្ញុំត្រូវបានហៅឱ្យចូលទៅក្នុងការិយាល័យរបស់ប៊ីស្សព មើរវ៉េ អលត៍ ហើយលោកបានផ្ដល់ការហៅ មួយដល់ខ្ញុំ ឱ្យបំរើជាប្រធាននៃក្រុមឌីកុន។ លោកបានប្រាប់ខ្ញុំថា ខ្ញុំត្រូវត្រឡប់ទៅផ្ទះ ហើយអធិស្ឋានថាតើនរណាគួរជាទីប្រឹក្សារបស់ខ្ញុំ។ លោកបានបង្រៀនខ្ញុំថា ព្រះអម្ចាស់នឹងជួយខ្ញុំក្នុងការធ្វើការសំរេចចិត្ត។ ទ្រង់ជួយពិតមែន។ ក្រោយមកខ្ញុំបានរៀនអំពីទីប្រឹក្សា ហើយខ្ញុំចាប់ផ្ដើមមើលឃើញថា តើហេតុអ្វីបានជាព្រះអម្ចាស់ឱ្យសាសនាចក្ររបស់ទ្រង់ដឹកនាំដោយគណៈប្រធាន មិនមែនមានតែប្រធានមួយរូប។ ខ្ញុំស្រឡាញ់ទីប្រឹក្សារបស់ខ្ញុំនៅក្នុងក្រុមឌីកុន ហើយយើងបានអធិស្ឋាន និងធ្វើការខ្លាំងដើម្បីជួយក្មេងប្រុសទាំងឡាយ ដែលនៅក្នុងក្រុមរបស់យើង។ ប៊ីស្សពហុល បានបង្រៀនខ្ញុំនូវគំរូនៃគណៈប្រធាន ហើយបានបង្រៀនខ្ញុំ នូវរបៀបដែលគណៈប្រធានគួរតែប្រតិបត្តិការ និងធ្វើការនៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់។

ក្រោយមក ពេលខ្ញុំបំរើជាប្រធាននៃក្រុមដទៃទៀត ខ្ញុំបានដឹងរួចជាស្រេចនូវសារៈសំខាន់នៃទីប្រឹក្សា ហើយខ្ញុំបានដឹងថាព្រះអម្ចាស់នឹងជួយខ្ញុំឱ្យជ្រើសរើសទីប្រឹក្សា---គឺដូចជាប៊ីស្សពបានបង្រៀនដល់ខ្ញុំ។

ក្នុងនាមជាប្រធានក្រុមឌីកុន ហើយក្រោយមកជាប៊ីស្សព និងជាប្រធានស្ដេក ខ្ញុំបានដឹងថារាល់ប្រាជ្ញា និងការយល់ដឹង ឬសមត្ថភាពដែលខ្ញុំមាន វានឹងលើកដំកើងយ៉ាងសំខាន់ នៅពេលខ្ញុំបានរួមបញ្ចូលទីប្រឹក្សារបស់ខ្ញុំនៅគ្រប់ការធ្វើការសំរេចចិត្តដែលត្រូវធ្វើឡើង។ ខ្ញុំបានដឹងថា អត្ថប្រយោជន៍នៃការបំរើជាមួយគ្នាជាគណៈប្រធានគឺជារឿងល្អណាស់ ហើយជាការលើកដំកើង។

ខ្ញុំចាប់ផ្ដើមយល់នូវមូលហេតុដែលព្រះអម្ចាស់បានតែងតាំងថា សាសនាចក្ររបស់ទ្រង់គួរតែត្រូវបានដឹកនាំដោយ ពួកសង្ឃជាន់ខ្ពស់ត្រួតត្រាបីនាក់ និងមូលហេតុដែលទំរង់នៃភាពជាអ្នកដឹកនាំ គួរតែត្រូវបានដឹកនាំនៅទូទាំងសាសនាចក្រ។

ព្រះអម្ចាស់បានមានបន្ទូលថា: "យើងនឹងប្រទានគំរូដល់អ្នក អំពីគ្រប់ទាំងអស់ ដើម្បីកុំឱ្យអ្នករាល់គ្នាអាចត្រូវគេបញ្ឆោតបាន" (គ. និង ស. 52:14)។ ទ្រង់បានប្រទានគំរូនៃភាពជាអ្នកដឹកនាំដល់យើង។ លើកលែងតែក្រុមសាវក 12 នាក់ និងពួក 70 នាក់ ក្រុមទាំងអស់ នៃសាសនាចក្រគឺត្រូវបានដឹកនាំដោយប្រធានមួយរូប និងទីប្រឹក្សាពីររូប។ លើសពីនេះទៀត អង្គការជំនួយ នៅគ្រប់ថ្នាក់ទាំងអស់ត្រូវបានដឹកនាំដោយប្រធានមួយរូប និងទីប្រឹក្សាពីររូប។ ពរជ័យ និងអត្ថប្រយោជន៍ទាំងអស់ នៃការបំរើជាមួយគ្នា ជាគណៈប្រធាន អនុវត្តចំពោះអង្គការជំនួយទាំងអស់ ក៏ដូចជាក្រុមបព្វជិតភាពផងដែរ។

យើងម្នាក់ៗដែលបំរើនៅក្នុងគណៈប្រធាន នៅគ្រប់ទីកន្លែងនៅក្នុងសាសនាចក្រ គួរតែមើលទៅគណៈប្រធានទីមួយជាគំរូ និងជាឧទាហរណ៍របស់យើង ដែលយើងស្វែងធ្វើតាម នៅពេលយើងអនុវត្តកិច្ចការរបស់យើង។ យើងគួរតែព្យាយាមធ្វើឱ្យដូចពួកលោក ហើយធ្វើការជាមួយគ្នានៅក្នុងសេចក្ដីស្រឡាញ់ និងសេចក្ដីក្សេមក្សាន្តដូចដែលពួកលោកបានធ្វើ។

ជាញឹកញាប់ប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី បានមានប្រសាសន៍អំពីសារៈសំខាន់នៃទីប្រឹក្សាៈ លោកបានមានប្រសាសន៍ថាៈ "ព្រះអម្ចាស់បានដាក់ពួកគេ [ទីប្រឹក្សា] នៅទីនោះសំរាប់គោលបំណងមួយ" (*Teachings of Gordon B. Hinckley* [1997], 94)។

ប្រធានហ្គរដុន ប៊ី ហ៊ិងគ្លីបន្តបង្រៀនយើងទៀតថាៈ "រាល់ព្រឹក លើកលែងតែថ្ងៃច័ន្ទ គណៈប្រធានទីមួយជួបជុំគ្នា (នៅពេលដែលយើងនៅក្នុងក្រុង)។ ខ្ញុំទូរស័ព្ទទៅប្រធាន ហ្វោស្ត ឱ្យប្រាប់ពីកិច្ចការរបស់លោក ហើយយើងពិភាក្សាអំពីកិច្ចការនោះ និងធ្វើការសំរេចចិត្ត។ បន្ទាប់មក ទូរស័ព្ទទៅប្រធាន ម៉នសុន ឱ្យប្រាប់ពីកិច្ចការរបស់លោក ហើយយើងពិភាក្សាអំពីកិច្ចការនោះ និងធ្វើការសំរេចចិត្ត។ បន្ទាប់មក ខ្ញុំប្រាប់នូវកិច្ចការដែលខ្ញុំចង់បង្ហាញ ហើយយើងពិភាក្សាជាមួយគ្នា និងធ្វើការសំរេចចិត្ត។ យើងធ្វើការជាមួយគ្នា។ អ្នកមិនអាចជាមនុស្សតែម្នាក់ដែលប្រតិបត្តិការនៅក្នុងគណៈប្រធាននោះទេ។ ទីប្រឹក្សា---ទីប្រឹក្សាគឺអស្ចារ្យណាស់។ ទីប្រឹក្សាជួយអ្នកមិនឱ្យធ្វើខុសឆ្គង ពួកគេជួយអ្នកឱ្យធ្វើរឿងត្រឹមត្រូវ...។"(*Teachings of Gordon B. Hinckley* 95 សូមមើលផងដែរ "នៅក្នុង Counselors There is Safety" *Ensign,* ខែវិច្ឆិកា ឆ្នាំ 1990, 48--51)។

ទីប្រឹក្សាមួយរូបរបស់ប្រធានយ៉ូសែប អែហ្វ ស៊្មីធ នៅពេលមួយបានពិពណ៌នាអំពីរបៀប ដែលគណៈប្រធានទីមួយធ្វើការពិគ្រោះគ្នាថាៈ "នៅពេលមានករណីមួយកើតឡើងចំពោះ [ប្រធាននៃសាសនាចក្រ] ត្រូវធ្វើការវិនិច្ឆ័យលោក និងទីប្រឹក្សារបស់លោក នឹងលើកយកមកពិភាក្សាម្ដងទៀត ហើយធ្វើ*ការពិចារណាយ៉ាងយកចិត្តទុកដាក់រហូតដល់ពួកលោកមាននូវការសន្និដ្ឋានដូចគ្នា* " (Anthon H. Lund នៅក្នុង Conference Report, June 1919, 19 បន្ថែមការសង្កត់បញ្ជាក់)។ នោះគួរតែជាគំរូរបស់យើងនៅក្នុងគណៈប្រធាន។

វិវរណៈបង្រៀនយើងឱ្យធ្វើការសំរេចចិត្តជាក្រុម និងជាគណៈប្រធានថាៈ "ដោយសេចក្ដីសុចរិត ដោយបរិសុទ្ធភាព និងចិត្តសុភាពរាបសារ ស្លូតបូត និងសេចក្ដីអត់ធ្មត់ និងដោយសេចក្ដីជំនឿ និងគុណធម៌ និងដឹងខ្លួន សេចក្ដីអត់សង្កត់ សេចក្ដីអត់ធន់ សេចក្ដីកោតខ្លាចដល់ព្រះ សេចក្ដីរាប់អានគ្នា និងសេចក្ដីសប្បុរស" (គ. និង ស. 107:30)។

ព្រះអម្ចាស់បានប្រទានដល់យើងនូវគំរូមួយ។ នៅថ្ងៃនេះយើងបានគាំទ្រគណៈប្រធានទីមួយថ្មីនៃសាសនាចក្រ ។ ពួកលោកបង្រៀនយើង ហើយបង្ហាញយើងនូវគំរូ ដែលយើងគួរតែធ្វើតាម។ ប្រាជ្ញា និងកម្លាំងនឹងប្រទានដល់យើងនៅពេលយើងមើលទៅគណៈប្រធានទីមួយ ជាខ្នាតគំរូ និងគំរូនៃភាពជាអ្នកដឹកនាំរបស់យើង។

ពរជ័យដ៏មហិមានឹងប្រទានដល់ក្រុមគ្រួសាររបស់យើង នៅពេលយើងបង្រៀនកូន និងចៅរបស់យើងឱ្យស្រឡាញ់ និងគាំទ្រដល់ពួកអ្នកដឹកនាំនៃសាសនាចក្រ។ កាលពីនៅក្មេង ពេលឈរនៅក្នុងផ្ទះរបស់លោកយាយលោកតារបស់ខ្ញុំ ខ្ញុំបានដឹងថា យើងត្រូវបានដឹកនាំដោយពួកបុរសនៃព្រះ ដែលព្រះអម្ចាស់បានដាក់ឱ្យនៅទីនោះដើម្បីដឹកនាំយើង។

ឥឡូវខ្ញុំដឹងហើយ។ ខ្ញុំសូមថ្លែងជាសាក្សីថា នេះគឺជាកិច្ចការនៃព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ហើយថាយើងត្រូវបានដឹកនាំដោយពួកសាវក និងពួកព្យាការីរបស់ទ្រង់។ ខ្ញុំសូមថ្លែងជាសាក្សីថា សាវកច្បង ប្រធាន ថូម៉ាស អេស ម៉នសុន

បានត្រូវហៅដោយព្រះ ហើយថាព្រមជាមួយនឹងទីប្រឹក្សាទាំងពីររូបដែលនៅក្បែរលោក ពួកលោកនឹងដឹកនាំយើងស្រប តាមគំនិត និងព្រះទ័យនៃព្រះអម្ចាស់ ដែលសាសនាចក្រនេះជារបស់ទ្រង់។ នៅក្នុងព្រះនាមពិសិដ្ឋនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។